# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ

## ថ្នាក់ទី ៦ – ការិយាល័យផ្នែកសាលា និង សិក្សាធិការ

*Parent Study Guide for 6th Graders (Khmer)*

# ការអាន និង ការសរសេរ

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

- ពន្យល់ពីមធ្យោបាយ ដែលគេយកមកប្រើ ដើម្បីស្វែងយល់នៅ មុនពេលអាន ពេលអាន និងក្រោយពេលអាន ដូចជា ក្បួន Talk Across the Fingers, 5 Ws និង TAG It a 3
- អាន និងយល់អត្ថបទច្រើនប្រភេទ រួមទាំងរឿងប្រឌិតពីប្រវត្តិសាស្ត្រ ប្រលោមលោក កំណាព្យ រឿងព្រេង (fairy tales, tall tales, myths, legends) និងរឿងល្ខោន
- អាន និងពិភាក្សាអត្ថបទព័ត៌មានផ្សេងៗ ដូចជា ទស្សនាវដ្តី អត្ថបទសារព័ត៌មាន អត្ថបទ វិទ្យាសាស្ត្រ និងសង្គមសាស្ត្រ
- ប្រើការប៉ិនប្រសប់ក្នុងការសរសេរ ដើម្បី គ្រោង ព្រាង កែសម្រួលឡើងវិញ និងផ្សាយការ សរសេរ តាមគោលបំណងអ្វីមួយ
- សរសេរអត្ថបទច្រើនប្រភេទ ដូចជាសរសេររឿង ល្ខោន កំណាព្យ និងរបាយការណ៍



# គណិតសាស្ត្រ

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

- ដោះស្រាយគណិតសាស្ត្រ ដោយប្រើក្បួនគិតលេខ និងទំនាក់ទំនងរបស់លេខ ជាមួយនឹង ប្រភាគ ទសភាគ លេខមានសញ្ញា និងភាគរយ
- ប្រើម៉ាស៊ីនគិតលេខ ដើម្បីគិតលេខពិបាកៗ
- ធ្វើ ផែក និងបញ្ជាក់ការប្រមាណ ហើយពន្យល់ពីយោបល់របស់ខ្លួន
- ប្តូរខ្នាតធម្មតា និងខ្នាតម៉ែត្រ តាមរង្វាស់ដូចគ្នា ដូចជា ប៉ុន្មានអ៊ីង ក្នុងមួយយ៉ាដ
- ដោះស្រាយគណិតសាស្ត្រដែល ទាក់ទងទៅនឹងបរិវេណ ផ្ទៃក្រឡា និង ចំណុះ
- ចង្អុលបង្ហាញមុំផ្សេងៗ (មុំស្រួច តិចជាង ៩០ មុំកែង = ៩០ មុំទាល ច្រើនជាង ៩០)
- គូររូបតាមការប្រមាណទំហំ
- រកវិធីល្អបំផុត សម្រាប់បង្ហាញ និងបកប្រែស្ថិតិ ក្នុងសំណុំមួយ
- រៀបរាប់សំណុំស្ថិតិ ប្រើមធ្យមភាគ លេខនៅកណ្តាល លេខញឹកញាប់ និងលេខចន្លោះ (ពីលេខធំបំផុត ទៅ តូចបំផុត)
- រកឱកាសនៃព្រឹត្តិការណ៍សាមញ្ញមួយ ដែលអាចកើតឡើង ឧទាហរណ៍ “តើមានឱកាសបានក្បាលប៉ុន្មានដង នៅពេលបោះកាក់ឡើងលើ?”
- ពិនិត្យមើលលំនាំមួយ ហើយសម្រេចថា តើមានអ្វីកើតឡើង បន្ទាប់ទៀត។ ឧទាហរណ៍ ៧ ១២ ១៧ ២២,... (ក្បួនតម្រូវឲ្យបូក លេខ៥ ដើម្បីបានលេខ២៧ ជាបន្ត)
- រកចំណុច និង គូសចំណុច នៅលើខ្សែអាក់
- ពន្យល់ពាក្យគណិតវិទ្យាសម្រាប់រូបរាង (ខ្សែស៊ីមេទ្រី/សមប្បមាណ ការធ្វើគំនូរវិចិត្រ ចាំងត្រឡប់ វិលជុំវិញ បរិវត្តន៍ ស្របគ្នា កាត់កែង ស្រដៀងគ្នា និង ដូចគ្នា)
- ចង្អុលបង្ហាញ និងវាស់ផ្នែកផ្សេងៗនៃរង្វង់ (ចំណុចកណ្តាលកាំ បរិវេណជុំវិញ មុំកណ្តាល និង បន្ទាត់ផ្ចិត

# វិទ្យាសាស្ត្រ

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

- បណ្តុះបណ្តាលការប៉ិនប្រសប់ ដែលសង្កត់ទៅលើការប្រើវិញ្ញាណទាំងប្រាំ នៅពេលរៀនវិទ្យាសាស្ត្រ
- បង្កើតសំណួរតាមការសង្កេតពិនិត្យ
- បញ្ចេញមតិទូទៅ ចំពោះលទ្ធផលនៃការពិសោធន៍
- អនុវត្តក្បួនគណិតវិទ្យា ក្នុងវិធីវិទ្យាសាស្ត្រ
- រៀនឲ្យមានការយល់ដឹងពីទស្សនៈ នៃវិទ្យាសាស្ត្រផែនដី ដោយប្រើវត្ថុគំរូ និង ផែនទី
- សង្កេតមើល ឥទ្ធិពលរបស់ទឹក ដែលបង្កើតឲ្យមានរូបរាងផែនដី
- បកប្រែទ្រឹស្តីវិទ្យាសាស្ត្រ អំពីទម្រង់សាកលលោក
- រៀបរាប់សង្ខេបអំពី ប្រវត្ត និងអនាគត នៃការហោះហើរ របស់មនុស្សលោក
- ពន្យល់ពីសេចក្តីត្រូវការ ដើម្បីអភិវឌ្ឍន៍អាកប្បកិរិយានៃការគោរព និងយល់ដឹងពីជីវិត។ រៀបរាប់អំពីការផ្លាស់ប្តូរលក្ខណៈបរិដ្ឋាន ដោយធម្មជាតិ និងដោយមនុស្សលោក ដែលអាចប៉ះទង្គិច ដល់ការរស់រានមានជីវិតរបស់ភាវៈ និងសត្វមានជីវិតទាំងអស់
- ធ្វើការស៊ើបអង្កេតដោយផ្ទាល់ ដើម្បីរកមើល និងយល់ពីពិភពលោក
- កត់ទុកការសង្កេតមើល ក្នុងសៀវភៅវិទ្យាសាស្ត្រ



# សង្គមសាស្ត្រ

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

- ពិភាក្សាពីយោបល់ និងមធ្យោបាយខាងហិរញ្ញវត្ថុ ដូចជា ការចាត់ចែងប្រាក់កាស និងអនុវត្តការចាត់ចែងទាំងនេះ ទៅលើជីវិតប្រចាំថ្ងៃ
- ប្រើលំនាំភូមិសាស្ត្រទាំងប្រាំយ៉ាង៖ ទីតាំង ចលនា ទីកន្លែង តំបន់ និងទំនាក់ទំនង ដើម្បីឆ្លើយសំណួរ និងវិភាគទស្សនៈ ផ្នែកភូមិសាស្ត្រ
- ចង្អុលបង្ហាញពីសារៈសំខាន់ តាមលំនាំចលនារបស់ប្រជាជន របស់របរ និងគំនិត ទៅតាមពេលវេលា និងទីកន្លែង
- ធ្វើវិភាគនូវទំនាក់ទំនងរវាង មនុស្ស និងបរិដ្ឋានដែលនៅជុំវិញ
- ពិភាក្សាពី ទឹកដី ប្រវត្តិសាស្ត្រ និងវប្បធម៌ របស់អាមេរិកឡាតាំង មានអនុភាពមកលើការអភិវឌ្ឍន៍ពិភពលោកខាងលិច
- ពន្យល់ពីភូមិសាស្ត្រនៃអាមេរិកខាងជើង ដែលមានមុខងារយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ និង ផ្សព្វផ្សាយវប្បធម៌ជនជាតិដើមអាមេរិក
- ប្រៀបធៀប និងរកមើលភាពខុសគ្នា រវាងប្រព័ន្ធនយោបាយនៃប្រទេសកាណាដា និងសហរដ្ឋអាមេរិក
- ពន្យល់ពីការអភិវឌ្ឍន៍របស់សហគមន៍ខ្មែរ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ៉ា
- ពិភាក្សាពីច្បាប់ដែលគ្រប់គ្រងប្រព័ន្ធយុត្តិធម៌យុវវ័យ នៅរដ្ឋផិនស៊ីលវេញ៉ា
- បង្ហាញការយល់ដឹង អំពីប្រវត្តិអាហ្វ្រិកាំង-អាមេរិកាំង

# សុខភាព/កាយសិក្សា

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

- យល់ពីឥទ្ធិពលរបស់ក្រុមផ្សាយព័តមាន ទៅលើអាកប្បកិរិយារបស់យុវវ័យ
- បង្ហាញពីចិត្តករុណា ដល់មនុស្សឈឺ
- យល់ថា ហេតុអ្វីបានជាតំណម គឺជាអាកប្បកិរិយាដ៏ល្អបំផុតសម្រាប់យុវវ័យ
- ដឹងពីផលវិបាកនៃការព្រួយបារម្ភ ទៅលើសុខភាព និងអាកប្បកិរិយា
- ពន្យល់ពីការចេះដឹងនៃការប៉ិនប្រសប់ផ្នែកកីឡា
- រៀបចំគំរោងហាត់ប្រាណផ្ទាល់ខ្លួន

# សិល្បៈ និងតន្ត្រី

នៅពេលបញ្ចប់ឆ្នាំសិក្សា ក្មេងថ្នាក់ទី៦ ត្រូវចេះ៖

**សិល្បៈ**

- យល់ពីការប្រើព៌ណ ខ្សែបន្ទាត់ និងរាង ដើម្បីបង្កើតសិល្បៈគំនូរ
- រៀបរាប់ពីប្រធានបទ សញ្ញា ឬគំនិត នៅក្នុងសិល្បៈមួយ ដោយប្រើពាក្យសិល្បៈ
- សរសេររៀបរាប់ ពីមតិរបស់ខ្លួន ចំពោះសិល្បៈណាមួយ

**តន្ត្រី**

- ច្រៀង និងលេងភ្លេង តាមក្បួនតន្ត្រី ពីរ ឬបីយ៉ាង ដោយប្រើអក្សរភ្លេងត្រឹមត្រូវ និងសមស្រប
- ដឹង និងបង្ហាញពីបែបបទ និងប្រភេទខុសៗគ្នារបស់តន្ត្រី ដោយច្រៀង និងលេង ឧបករណ៍ភ្លេង